ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
លេខ:៣៥៨/២៥-៤-២០១១
សាលដីកា
លេខ:៦៩ ក្រ.IV.ត/២៥-០៩-២០១២

## គាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៥ខែកញ្ញា ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ:៣៥៨ចុះថ្ងៃទី២៥-៤-២០១១

រវាង៖

-ជនជាប់ចោទឈ្មោះ [redacted] សំអឿនហៅភាព ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរមុខរបរគ្រូបង្រៀន ទីកន្លែងកំណើតភូមិកោះប្រាក់ ឃុំកោះទន្ទឹម ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃភូមិ [redacted] ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន។ ក្រៅឃុំ (ដើមបណ្តឹងឧទ្ធរណ៍)

<u>ត្រូវចោទពីបទ:</u> បរិហាកេរ្តិ៍ ប្រព្រឹត្តិនៅភូមិព្រែកជីក សង្កាត់សំបូរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃទី២៩-០៦-២០១០ ។ បទល្មើសមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៦៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។/





Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរ បោះពុម្ព មានទីលំនៅសព្វថ្ងៃ [redacted]។

មេធាវីលោក [redacted] បូរាណ

ឯរឿងហេតុមានដូចតទៅ៖

តាមពាក្យបណ្តឹងចុះថ្ងៃទី០២ខែកក្កដា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] បានប្តឹងពីឈ្មោះ [redacted] សំអឿន ពីបទបរិហាកេរ្តិ៍ថាខ្លួនមានសហាយជាមួយប្តីគាត់ឈ្មោះវ៉ា ស្រៀង ព្រមទាំងនិយាយតាមទូរស័ព្ទថា ឲ្យខ្លួនប្រយ័ត្នខ្លួន ប្រយ័ត្នជះទឹកអាស៊ីត។ក្នុងរឿងនេះ ខ្លួនទាមទារសំណងជម្ងឺចិត្ត កិត្តិយស ពីឈ្មោះ [redacted] សំអឿន ចំនួន ៥.០០០.០០០៛និងសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៥"ខ"ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពង់ចាម ដែលមានខ្លឹមសារដូចតទៅ៖

១-ផ្តន្ទាទោស

ពិន័យជាប្រាក់ចំនួន១.០០០.០០០៛(មួយលានរៀល)ដាក់ចូលថវិការដ្ឋលើឈ្មោះអ៊ូ សំអឿនហៅភាព ពីបទបរិហាកេរ្តិ៍ ប្រព្រឹត្តិនៅភូមិព្រែកជីក សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា៦៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៦៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់ឲ្យឈ្មោះ [redacted] សំអឿន ហៅភាព សងសំណងជម្ងឺចិត្តឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ចំនួន១.០០០.០០០៛(មួយលានរៀល) ការសុំលើសពីនេះបដិសេធចោល។

៣-សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១១ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំអឿន និងមេធាវីតំណាងផ្ទេរសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សំអឿន ហៅភាព និងចំពោះមុខមេធាវីតំណាងផ្ទេរសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញសេចក្តីប្តឹងតវ៉ាចុះថ្ងៃទី២៨-០២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សំអឿន ហៅភាព ប្តឹងឧទ្ធរណ៍នឹងសេចក្តីសំរេចនៃសាលក្រមព្រហ្មទណ្ឌលេខ០៥ "ខ"ថ្ងៃទី១៩ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពង់ចាម ត្រង់ចំណុចនៃសាលក្រមទាំងមូល។

បានឃើញរបាយការណ៍ចុះថ្ងៃទី១៥-៧-២០១១ របស់ចៅក្រមសាលាឧទ្ធរណ៍។

<u>នាពេលសវនាការ</u>

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] សំអឿនបានឆ្លើយបញ្ជាក់ថា ខ្លួនមិនបាននិយាយបរិហាកេរ្តិ៍ទេ គ្រាន់តែនៅពេលដើមបណ្តឹងទូរស័ព្ទមកប្តីខ្លួន ខ្លួនក៏បានប្រាប់ថា លេខនេះតេមកប្តីខ្លួនច្រើនដងហើយ ប្រយ័ត្នទៅ ។ ក្រោយមកមានមនុស្សប្រុសម្នាក់មកជេរខ្លួនដល់ផ្ទះហើយខ្លួនមិនដែលសុំទោសគេទេ



Scanned with CamScanner

ប្ដីដើមបណ្ដឹងធ្វើប៉ូលីសខ្លួនខ្លាចគេមានកាភ្លេង។ ខ្លួនមនស្គាល់ឌឿន ភឿន ទេ ហើយខ្លួនធ្លាកាបូបលុយប្ដីខ្លួនឃើញមានរូបថតមានសរសេរធីណា បូក ស្រៀន និងមានសារតាមទូរសព្ទជាភាសាអង់គ្លេសដាក់ថា ធីណាស្រឡាញ់វ៉ា ស្រៀន ចង់ដេក ចង់ថើបវ៉ា ស្រៀន ខ្លួនស្គាល់ធីណាព្រោះគាត់ធ្លាប់មកផ្ទះខ្លួន ។

-តំណាងមហាអយ្យការផ្តល់សេចក្ដីសន្និដ្ឋានៈ

សុំក្រុមប្រឹក្សាពិនិត្យឡើងវិញលើចម្លើយពាក់ពន្ធ័ លើសារភាគីម្ខាងទៀត និងសាក្សីក្នុងរឿង សុំជូនក្រុមប្រឹក្សាសម្រេចតាមច្បាប់។

-មេធាវីសន្និដ្ឋានៈកូនក្ដីខ្លួនប្ដឹង [redacted] សំអៀន បទបរិហាកេរ្តិ៍ ហើយថ្ងៃកើតហេតុកូនក្ដីខ្លួនទូរសព្ទ័ទៅទារលុយ វ៉ា ស្រៀន ថ្លៃថតចម្លងស្រាប់តែមានស្រីម្នាក់ជេរប្រមាថថាកុំឲ្យកូនក្ដីខ្លួនទាក់ទងប្ដីគាត់ ហើយកូនក្ដីរបស់ខ្លួនក៏បាននិយាយប្រាប់ប្ដីរបស់គាត់ហើយឧបគ្គាទៅសួរកេខុសត្រូវ។សុំក្រុមប្រឹក្សាពិចារណា ចំពោះសារជាភាសាអង់គ្លេស កូនក្ដីខ្លួនមិនចេះអង់គ្លេសទេ សុំតម្កល់សាលក្រម។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

១-បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៨-០២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សំអៀន ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ០៥ "ខ" ចុះថ្ងៃទី១៩-០១-២០១១(ទទួលថ្ងៃទី២១-០២-២០១១) របស់សាលាដំបូងខេត្តកំពង់ចាម ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-ជនជាប់ចោទបានឆ្លើយបដិសេធ ប៉ុន្តែសាក្សីឈ្មោះ ឌឿន ភឿន បានឮឈ្មោះអ៊ូ សំអៀននិយាយសុំទោសថា"ខ្ញុំសុំទោស ខ្ញុំនិយាយហួសហើយ"។សាក្សីឈ្មោះ ឈុន គឹមម៉េង ខ្លួនជាអ្នកផ្ញើសារលេងសើចជាមួយឈ្មោះ វ៉ា ស្រៀន ដោយឈ្មោះ ស៊ាង ធីណា មិនដឹងទេ។តាមអង្គហេតុនៃរឿងនេះ អាចឲ្យជឿបានថា ជនជាប់ចោទពិតជាបាននិយាយថាជនរងគ្រោះសាហាយជាមួយប្ដីខ្លួន ដូចបានសំអាងហេតុក្នុងសាលក្រមសាលាដំបូង។

៣-សាលក្រមព្រហ្មទណ្ឌលេខ០៥ "ខ" ចុះថ្ងៃទី១៩-០១-២០១១ របស់សាលាដំបូងខេត្តកំពង់ចាម បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ ។

## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៨-០២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សំអៀន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។



Scanned with CamScanner

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ០៥ "ខ" ចុះថ្ងៃទី១៩-០១-២០១១ របស់សាលាដំបូងខេត្តកំពង់ចាមទុកជាបានការ ។

សាលដីកានេះ ជំនុំជំរះចំពោះមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកានិងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
| --- | --- | --- |
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]



Scanned with CamScanner